# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល
(អេឃ្វីប)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# វគ្គតំរង់ទិសស្តីអំពីកម្មវិធីបំណិនជីវិត

សម្រាប់

សមាជិកក្រុមចំបង,នាយក,គ្រូ និង តំណាងសហគមន៍




ព្រាងជាថ្មី ខែមករា ឆ្នាំ២០០៧

យោងតាមឯកសាររបស់អង្គការ

# សិក្ខាសាលាតម្រង់ទិស អំពីបំណិនជីវិតទូទៅ និង បំណិនជីវិតវប្បធម៌

## សំរាប់ក្រុមចំបងទទួលបន្ទុកបំណិនជីវិត និង ក្រុមគាំទ្រកម្មវិធីបំណិនជីវិតប្រចាំសាលា

| លរ. | មាតិកា | រយៈពេល | ទំព័រ |
|---|---|---|---|
| **1** | **ការផ្តើមសិក្ខាសាលា** | | |
| 1.1 | ការណែនាំឱ្យស្គាល់គ្នា/កំណត់បទបញ្ជា ពេលវេលាសម្រាប់សិក្ខាសាលា | **08 : 00 – 08 : 15**<br>១៥ នាទី | |
| 1.2 | គោលបំណងសិក្ខាសាលា/គោលដៅ/ផលរំពឹងទុក | | |
| **2** | **ការពីពណ៌នាពីកម្មវិធីបំណិនជីវិត** | | |
| 2.1 | គោលបំណងកម្មវិធីបំណិនជីវិត/ក្រុមគោលដៅ/សារៈសំខាន់ | **08 : 15 – 08 : 45**<br>៣០ នាទី | |
| 2.2 | ដំណើរការកម្មវិធីបំណិនជីវិត(ជំហាន) | | |
| **3** | **វិធីសាស្ត្រក្នុងការអនុវត្ត** | | |
| 3.1 | វិធីបំផុសសិស្សអោយរកជំនាញ និង ការរៀបចំសិស្សចុះស្រាវជ្រាវ | **08 : 45 – 09 : 15**<br>៣០ នាទី | |
| | **សំរាក** | ១៥ នាទី | |
| 3.2 | របៀបដឹកនាំសិស្សធ្វើថ្នាក់ទិទស្សន៍ | **09 : 30 – 10 : 00**<br>៣០ នាទី | |
| 3.3 | ការជ្រើសរើសយកជំនាញ ការរៀបចំក្រុមសិស្សតាមជំនាញ និង ការកំណត់គ្រូបំណិនជីវិត ដោយផ្អែកលើប្រមូលពតិមានដែលសិស្សប្រមូលបាន។ | **10 : 00 – 11 : 00**<br>៦០ នាទី | |
| 3.4 | ការប្រជុំតម្រង់ទិសលើកទី១ ដល់ គ្រូបំណិនជីវិត និង មាតាបិតាសិស្ស | **11 : 00 – 11 : 30**<br>៣០ នាទី | |
| **សំរាក អាហារថ្ងៃត្រង់** | | | |
| 3.5 | ការធ្វើផែនការមេរៀនជាមួយគ្រូបំណិនជីវិតៈ | **02 : 00 – 02 : 30**<br>៦០ នាទី | |
| 3.6 | ការកំណត់ថវិការ | **02 : 30 – 03 : 30**<br>៦០ នាទី | |
| | **សំរាក** | ១៥ នាទី | |
| **4** | ផែនការសកម្មភាពសំរាប់អនុវត្តកម្មវិធីបំណិនជីវិតវប្បធម៌តាមសាលា | **03 : 45 – 04 : 00**<br>១៥ នាទី | |

<u>សំគាល់:</u>

ព្រឹកៈ ៨:00 -11:30          ល្ងាចៈ 2:00 – 4:00

រយៈពេល១ថ្ងៃ សម្រាកៈ ព្រឹក ១៥ នាទី ល្ងាច ១៥ នាទី

អង្គការអប់រំពិភពលោក

WORLD EDUCATION

# កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

(អេឃ្វីប)

# ឯកសារសម្រាប់អ្នកសម្របសម្រួល

## វគ្គតម្រង់ទិសស្តីពីបំណិនជីវិត

សម្រាប់

## សមាជិកក្រុមចម្លង, នាយក, គ្រូ និង តំណាងសហគមន៍

ខែមករា ឆ្នាំ២០០៧

# ការតម្រង់ទិសអំពីបំណិនជីវិត(ទូទៅនិងវប្បធម៌)ដល់សមាជិកក្រុមចំបងទទួលបន្ទុកបំណិនជីវិតនិង ក្រុមគាំទ្រកម្មវិធីបំណិនជីវិតប្រចាំសាលា (គ្រូស្ម័គ្រចិត្ត និង តំណាងសហគមន៍)

| **វគ្គទី១: សេចក្ដីផ្ដើមសិក្ខាសាលា,គោលបំណង និង លទ្ធផលដែលរំពឹងទុក** | | |
|---|---|---|
| ខ្លឹមសារនិងសេចក្ដីសង្ខេប:<br><br><br><br><br>រយៈពេល: | **១. ការផ្ដើមសិក្ខាសាលាៈ** នេះជាការចាប់ផ្ដើម ដោយអ្នកសម្របសម្រួល និង សិក្ខាកាមណែនាំ ខ្លួនម្ដងម្នាក់ៗដើម្បីអោយស្គាល់គ្នាទៅវិញទៅមក ។ ធ្វើការពិនិត្យមើលកម្មវិធីសិក្ខាសាលាទាំងមូល និង បង្កើតនូវ បទបញ្ជាមួយសម្រាប់អនុវត្តក្នុងសិក្ខាសាលា ។<br>ប្រសិនបើសិក្ខាកាមធ្លាប់បានស្គាល់គ្នាច្បាស់លាស់រួចមកហើយនោះការណែនាំមិនគួរចំណាយពេលយូរពេកទេ ។<br>៥ នាទី | |
| សម្ភារដែលត្រូវការៈ | ▪ ឯកសារចែកស្ដីអំពីកម្មវិធីសិក្ខាសាលា | |
| វត្ថុបំណង | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពអ្នកចូលរួម* |
| ▪ បង្កភាពងាយស្រួលក្នុងការពិភាក្សាគ្នា ។<br><br><br>▪ សិក្ខាកាមបានស្គាល់គ្នាកាន់តែច្បាស់ងាយស្រួលក្នុងការរៀនសូត្រពីគ្នា ។<br><br>▪ កំណត់ពីពេលវេលា និង បង្កើតនូវ បទ បញ្ជាមួយសម្រាប់អនុវត្តក្នុង សិក្ខាសាលាដើម្បីអោយដំណើរការប្រកបដោយប្រសិទ្ធភាព ។ | **១.១. ការចាត់ចែងអង្គុយតាមក្រុម**<br>មុនពេលចាប់ផ្ដើមសិក្ខាសាលា អ្នកសម្របសម្រួល គួរស្នើអោយអង្គុយជារាងអក្សរ U ដើម្បីឱ្យសិក្ខាកាម មានឱកាសពេញលេញក្នុងការរៀនសូត្រពីគ្នាឯងតាមរយៈការពិភាក្សាឬធ្វើការជាក្រុម ។<br>**១.២. ការណែនាំឱ្យស្គាល់គ្នា**<br>▪ អ្នកសម្របសម្រួលចាប់ផ្ដើមដោយការស្វាគមន៍ដ៏កក់ក្ដៅដល់សិក្ខាកាមទាំងអស់ហើយបន្តដោយការណែនាំខ្លួនអ្នកសម្របសម្រួល និង សិក្ខាកាម ម្នាក់ម្ដងៗ ។<br>**១.៣. បទបញ្ជាផ្ទៃក្នុង និង កម្មវិធី សំរាប់អង្គសិក្ខាសាលា**<br>▪ អ្នកសម្របសម្រួលគួររំលឹកពីបទបញ្ជាផ្សេងៗសម្រាប់អង្គសិក្ខាសាលា ដូចជា :<br>- ពេលវេលាចាប់ផ្ដើមសិក្ខាសាលា<br>- ពេលវេលាសម្រាក<br>- ថវិកា<br>▪ អ្នកសម្របសម្រួលដឹកនាំការពិភាក្សាដោយសរសេរលទ្ធផលពីដែលបានព្រមព្រាងលើក្រដាស់ធំ ដើម្បីអនុវត្តក្នុងរយៈពេលនៃអង្គសិក្ខាសាលា ។<br>▪ ចែកកម្មវិធីសិក្ខាសាលាហើយទុកពេលអោយសិក្ខាកាមអាន និង លើកជាសំណួរ ។ | ▪ សិក្ខាកាមជួយរៀបចំតុដើម្បីអង្គុយអោយមានលក្ខណៈងាយស្រួលក្នុងការពិភាក្សា ។<br><br>▪ សិក្ខាកាមប្រាប់ឈ្មោះ តួនាទី និងទីលំនៅ ។<br><br><br>▪ ពិភាក្សាគ្នាបង្កើតនូវ បទបញ្ជាមួយសម្រាប់អនុវត្តក្នុងសិក្ខាសាលា ។ |

| ខ្លឹមសារនិងសេចក្តីសង្ខេប: | **២. គោលបំណងសិក្ខាសាលា:**<br>នៅក្នុងផ្នែកនេះសិក្ខាកាមនឹងទទួលបាននូវការយល់ដឹងអំពី គោលបំណង និង លទ្ធផលដែលរំពឹងទុក នៃ សិក្ខាសាលានេះ ។ | |
|---|---|---|
| រយៈពេល: | ១០ នាទី | |
| សម្ភារដែលត្រូវការ: | ▪ ផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងសិក្ខាសាលា<br>▪ ឯកសារចែកទី១ ស្តីអំពីគោលបំណងសិក្ខាសាលា | |
| ▪ សិក្ខាកាមអាចរំលឹកពីផែនការកសាងកំរងសាលារៀនដែលបានពិនិត្យ និងឯកភាពដោយក្រុមការងារខេត្ត។<br><br>▪ សិក្ខាកាមអាចកំណត់ការរំពឹងទុករបស់ខ្លួនចំពោះសិក្ខាសាលា។<br><br>▪ ធ្វើការវាស់កំរិតយល់ដឹងរបស់សិក្ខាកាម។ | មូលហេតុ<br>▪ អ្នកសម្របសម្រួលពន្យល់ពីមូលហេតុដែលនាំអោយមានការប្រជុំនេះ។<br><br>កាលពីខែកញ្ញា២០០៥ គ្រប់កំរងសាលារៀនទាំងអស់បានរៀបចំ ផែនការកែលំអកំរងសាលារៀន ដោយកំរងធ្វើការជ្រើសរើស សកម្មភាពមួយចំនួនពីបញ្ជីសេវាកម្មរបស់កម្មវិធីអេស្កាប់ ។ ក្នុងនោះមានសាលាមួយចំនួន បានជ្រើសយកសកម្មភាព បំណិនជីវិតទូទៅ និង មួយចំនួនទៀតបំណិនជីវិតវិប្បធមិ និង សាលាខ្លះទៀត រើសយកទាំងពីរមុខសំរាប់អនុវត្តតាមសាលារបស់ខ្លួនតែទោះជាយ៉ាងនេះក៏ដោយសាលាទាំងនោះនៅមិនទាន់មានបទពិសោធន៍គ្រប់ គ្រាន់ ល្មមអាចដំណើរការសកម្មភាពនេះដោយ ខ្លួនឯង បានទេ។<br><br>ដូច្នេះគោលបំណងនៃសិក្ខាសាលាក្នុងថ្ងៃនេះគឺ<br>▪ អ្នកសម្របសម្រួលបិទផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងសិក្ខាសាលា( ឯកសារចែកទី១) រួចធ្វើការពន្យល់ពី គោលបំណង, គោលដៅ និង លទ្ធផលដែលរំពឹងទុក នៃ សិក្ខាសាលានេះ ។<br>▪ អ្នកសម្របសម្រួលលើកជាសំណួរដើម្បីសាកល្បងវាស់ស្ទង់ការយល់ដឹងរបស់សិក្ខាកាម។ ឧទាហរណ៍<br>- តើលទ្ធផលរំពឹងទុកសំខាន់បំផុតនៃសិក្ខាសាលានេះជាអ្វី?<br>- តើសិក្ខាសាលាថ្ងៃនេះផ្តោតជាសំខាន់ទៅលើអ្វីខ្លះ?<br>- តើសិក្ខាសាលានេះប្រព្រឹតទៅរយៈពេលប៉ុន្មានថ្ងៃ?<br>▪ អ្នកសម្របសម្រួលចែកឯកសារទី ១។ | ▪ សិក្ខាកាមរួមជាមួយអ្នកសម្របសម្រួលរំលឹកពីផែនការកសាងកំរងសាលារៀន។<br><br>▪ សិក្ខាកាមធ្វើការបញ្ជាក់ពីសាលារៀង៧ខ្លួនដែលបានស្នើសុំកម្មវិធីបំណិនជីវិតដែលបានលើកឡើងក្នុងផែនការ។<br><br>▪ សិក្ខាកាមឆ្លើយសំណួរដែលលើកឡើងដោយអ្នកសម្របសម្រួល ។ |

| វគ្គទី២: ការពណ៌នាពីកម្មវិធីបំណិនជីវិត | | |
|---|---|---|
| ខ្លឹមសារនិងសេចក្ដីសង្ខេប:<br><br><br>រយៈពេល: | **១. ការពណ៌នាពីកម្មវិធីបំណិនជីវិត: គោលបំណង, ក្រុមគោលដៅ និង សារសំខាន់:**<br>នៅក្នុងផ្នែកនេះសិក្ខាកាមនឹងទទួលបាននូវការយល់ដឹងអំពី គោលបំណងនៃកម្មវិធីបំណិនជីវិត និង និយមន័យនៃពាក្យបំណិនជីវិត និង គោលការណ៍សំខាន់នៃកម្មវិធីបំណិនជីវិត។<br>១០ នាទី | |
| សម្ភារដែលត្រូវការ: | ▪ ផ្ទាំងក្រដាសធំដែលមានសរសេរស្រាប់អំពីគោលបំណងនៃកម្មវិធីបំណិនជីវិត<br>▪ ឯកសារចែកទី២ ស្ដីអំពីគោលបំណងនៃកម្មវិធីបំណិនជីវិត | |
| ▪ សិក្ខាកាមអាចយល់ច្បាស់ពីគោលបំណងនៃកម្មវិធីបំណិនជីវិត។ | **ក/ គោលបំណងកម្មវិធីបំណិនជីវិត**<br>▪ អ្នកសម្របសម្រួលបិទក្រដាស់ធំដែលមានសរសេរពី គោលបំណង នៃកម្មវិធីបំណិនជីវិត<br><br>**<u>បំណងនៃកម្មវិធីបំណិនជីវិត</u>**<br>1. អនុវត្តសកម្មភាពបន្ថែមលើកម្មវិធីសិក្សាផ្លូវការក្រៅម៉ោង ដែលឆ្លើយតបទៅនឹងសេចក្ដី ត្រូវការរបស់កុមារ ហើយនិងជីវិត ជាក់ស្ដែងរបស់គេ ។<br>2. ផ្ដល់ឱកាសអោយកុមារធ្វើការសំរេចចិត្តជ្រើសរើសនូវអ្វីដែលគេចង់រៀន ។<br>3. ពង្រឹងទំនាក់ទំនងស្និទ្ធសាលរវាងសាលា និង សហគមន៍ ព្រមទាំងផ្ដល់ឱកាសអោយសហគមន៍ ចូលរួមក្នុងការរៀនសូត្រ របស់ កុមារ ។ | |
| ▪ សិក្ខាកាមអាចកំណត់ពីអត្ថន័យនៃពាក្យបំណិនជីវិត។<br><br>▪ ធ្វើការវាស់កំរិតយល់ដឹងរបស់សិក្ខាកាម។ | ▪ អ្នកសម្របសម្រួល បន្ទាប់មកធ្វើការសង្កត់ធ្ងន់លើអត្ថន័យនៃពាក្យ **បំណិនជីវិត** និងចាប់ផ្ដើមធ្វើការពិភាក្សា ដោយលើកជាសំណួរថា " តើបំណិនជីវិតជាអ្វី? "<br>▪ អ្នកសម្របសម្រួលធ្វើការកត់ត្រារាល់ចម្លើយទាំងអស់លើក្ដារខៀន។<br><br>**<u>បំណិនជីវិតគឺ:</u>**<br>- ជំនាញ/មុខរបរប្រចាំជីវិតឧ:លក់ដូរ ធ្វើនំ ត្បាញ រាំរបាំ។ល។<br>- វិធីរស់ឧ:កិច្ចទំនាក់ទំនង ការប្រើគំនិត ច្នៃប្រឌិត គិតដោយវិភាគ ការធ្វើការជាក្រុម ការសំរេចចិត្ត<br>- ចេះអក្ស លេខ ស្គាល់ពីតំលៃ នៃវប្បធម៌ សិទ្ធ<br>- មានការប៊ិនប្រសប់ មិនចាញ់បោកគេ នាំជីវិតទៅរកផ្លូវត្រូវ | ▪ សិក្ខាកាម ពិភាក្សាជាមួយដៃគូហើយផ្ដល់ ឆ្លើយ ។ |

| | | |
|---|---|---|
| សិក្ខាកាមមានលទ្ធភាពកំនត់ពីក្រុមគោលដៅតាមសាលារៀងៗខ្លួនដោយប្រើប្រាស់ស្ថានភាពជាក់ស្តែង ។<br><br><br><br><br><br><br><br><br><br>សិក្ខាកាមយល់ពីសារៈសំខាន់នៃកម្មវិធីបំណិនជីវិត ។ | **ខ/ ក្រុមគោលដៅ**<br>▪ អ្នកសម្របសម្រួលពន្យល់ថា គ្រប់សាលារៀនដែលអេស្កាប់គាំទ្រ ហើយបានលើកផែនការសំរាប់បំណិនជីវិតទូទៅ និងបំណិនជីវិត ទាក់ ទង នឹងវប្បធម៌ ។<br>▪ សាលានីមួយៗគួរតែ ជ្រើសរើសថ្នាក់ទី ៥ មួយថ្នាក់ និង ថ្នាក់ទី ៦ មួយថ្នាក់[១] មកអនុវត្តកម្មវិធីនេះដោយជ្រើសរើសយកមុខវិជ្ជាយ៉ាងច្រើនត្រឹមតែ ពីរសំរាប់បំណិនជីវិតនីមួយៗ ( គឺបំណិនជីវិតទូទៅ ២ មុខវិជ្ជា និងបំណិនជីវិត ទាក់ទង នឹងវប្បធម៌២ មុខវិជ្ជា ។<br>▪ សិស្សថ្នាក់ទី៥និងទី៦ដែលបានស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាពបន្ថែមលើកម្មវិធីសិក្សាផ្លូវការ ។<br>**គ/ សារៈសំខាន់ក្នុងការរៀបចំកម្មវិធីបំណិនជីវិត**<br>▪ អ្នកសម្របសម្រួលបិទក្រដាស់ធំដែលមានសរសេរពី សារៈសំខាន់ក្នុងការរៀបចំកម្មវិធីបំណិនជីវិត<br>1. សិស្សធ្វើការស្រាវជ្រាវដោយខ្លួនឯងដើម្បីស្គាល់ជំនាញ និង ធនធានមនុស្សដែលមានក្នុងសហគមន៍ របស់ខ្លួន ។<br>2. សិស្សជ្រើសរើសជំនាញមួយដែលគេចង់រៀនដកស្រង់ចេញពីបញ្ជីជំនាញដែលស្រាវជ្រាវឃើញពីក្នុង សហគមន៍ ។<br>3. សិស្សជ្រើសរើសមនុស្សពីសហគមន៍ដែលអាចធ្វើជាគ្រូ ។<br>4. កុមារសិក្សាជំនាញដែលគេបានជ្រើសរើសតាមក្រុមរបស់ខ្លួនដែលមានគ្នាពី ៤ -៥ នាក់ រៀងរាល់ ថ្ងៃ ព្រហស្បតិ៍ រយៈពេល ១ ម៉ោង រយៈពេល ១០ សប្តាហ៍ ។<br>5. សមាជិកម្នាក់ក្នុង ក្រុមចម្បងប្រចាំកម្រងសាលាទទួលបន្ទុកកម្មវិធីបំណិនជីវិតត្រូវចុះ ត្រួតពិនិត្យ សកម្មភាពបង្រៀន របស់ គ្រូសហគមន៍រៀងរាល់ថ្ងៃព្រហស្បតិ៍ ឬ ថ្ងៃអាទិត្យ ។<br>▪ អ្នកសម្របសម្រួល បន្ទាប់មកធ្វើការ ពន្យល់លើចំណុចសំខាន់ទាំងនោះដល់សិក្ខាកាម និង ចែកឯកសារទី ២ ។ | សិក្ខាកាមពីភាក្សាគ្នាពីស្ថានភាពជាក់ស្តែង និង កំណត់ថាតើត្រូវយកប៉ុន្មានថ្នាក់ ។ |



[១] ដោយឡែកសំរាប់សាលានៅតាមជនបទដែលសិស្សថ្នាក់ទី ៥ និង ទី៦មានចំនួនតិច យើងអាចបន្ថែមថ្នាក់បាន ។

| | | |
|---|---|---|
| **មេរៀន និងការសង្ខេប**<br><br>**រយៈពេល** | **២- ដំណើរការកម្មវិធីបំណិនជីវិតៈ** ផ្នែកនេះបង្ហាញដល់សិក្ខាកាមអំពី ក្រុមគោលដៅ ត្រូវ និងដំណើរការអនុវត្ត នៃ កម្មវិធី បំណិនជីវិតតាមជំហានណីមួយៗ និង អ្នកទទួលខុសត្រូវ ។<br>២៥ នាទី | |
| **សម្ភារះប្រើប្រាស់** | ១- ហ្វឹត<br>២- ឯកសារចែក | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| 1-សិក្ខាកាមអាចរៀបរាប់អំពីកម្មវិធីឡើងវិញបាន ។<br><br>2- អ្នកចូលរួមអាចយកចំណេះដឹងនេះទៅអនុវត្ត ។ | ▪ អ្នកសម្របសម្រួលចែកឯកសារទី៣ អំពី ដំណើរការអនុវត្ត កម្មវិធី ដល់សិក្ខាកាមអាន ។<br>▪ អ្នកសម្របសម្រួលធ្វើការបញ្ជាក់ច្បាស់អំពីលំដាប់លំដោយនៃការប្រតិបត្តិកម្មវិធី ជាពិសេសចាប់ពីជំហានទី៣ ទៅដែលជាជំហាន ដែលត្រូវប្រតិបត្តដោយអ្នកចូលរួម ។<br>▪ អ្នកសម្របសម្រួលលើកជាសំណួរដើម្បីសាកល្បងវាស់ស្ទង់ការយល់ដឹងរបស់សិក្ខាកាម ។ ឧទាហរណ៍<br>- តើបន្ទាប់ពីវគ្គតម្រង់ទិសនេះជំហានទី១ត្រូវធ្វើអ្វី? ទី២-ទី ៧ ?<br><br>**<u>ចម្លើយរំពឹងទុក</u>**<br>▪ រៀបចំតំរង់ទិសដល់សិស្សថ្នាក់ទី៥/ទី៦ និង ធ្វើការបែងចែកក្រុមសិស្សសំរាប់ធ្វើការស្រាវជ្រាវ ។<br>▪ សិស្ស ចុះស្រាវជ្រាវអំពីជំនាញ និង ធនធាន មនុស្សដែលមានក្នុងសហគមន៏ ។<br>▪ គ្រូនឹងជួយសិស្សរៀបចំ និង បង្ហាញពតិមាននឹងរៀបចំសីស្ស ជាក្រុមតូចៗ (៥ នាក់) តាមជំនាញដែល គេចង់រៀន និង កំនត់មនុស្សពីសហគមន៏ ដែលគេសុំអោយបង្រៀន ។<br>▪ សាលានីមួយៗគួរតែធ្វើពតិមានទាំងអស់នេះដល់សមាជិក ក្រុមចំបង និង ក្រុមការងារកម្មវិធី អេស្កាប់ប្រចាំខេត្ត ដើម្បីអោយគេជួយ រៀបចំថវិកា ។<br>▪ ក្រុមចំបងអញ្ជើញសំរាប់អ្នកដែលត្រូវបានជ្រើសរើសជាគ្រូសហគមន៏ និង មាតាបិតាសិស្ស ដើម្បីធ្វើការតំរង់ទិស ។<br>▪ អ្នកភូមិដែលយល់ព្រម ធ្វើគ្រូសហគមន៏ចូលរួមរៀបចំផែនការមេរៀនជាមួយក្រុមចំបង ។ | 1- អានឯកសារ<br>2- សួរ- ឆ្លើយ<br>3- ពិភាក្សា |

<table>
<tr><td colspan="3"></td></tr>
<tr><td>មេរៀន និងការសង្ខេប<br><br>រយះពេល</td><td colspan="2">៣- របៀបបំផុសគំនិត្យស្រាវជ្រាវរកជំនាញ និង ការរៀបចំសិស្សចុះស្រាវជ្រាវះផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី វិធីសាស្ត្រនានាដើម្បីអនុវត្តសកម្មភាពនិមួយៗ មុនពេលចុះ ស្រាវជ្រាវ ។<br>៦0 នាទី</td></tr>
<tr><td>សម្ភារះប្រើប្រាស់</td><td colspan="2">1- ក្រដាសផ្ទាំងធំ<br>2- ឯកសារចែក</td></tr>
<tr><td>វត្ថុបំណង</td><td>សកម្មភាពអ្នកសម្របសម្រួល</td><td>សក្មភាពអ្នកចូលរួម</td></tr>
<tr><td>1- សិក្ខាកាមបានដឹងពីដំណើរការអនុវត្ត ។<br><br>2- សិក្ខាកាមអាចប្រើឧបករណ៏និមួយៗជាមួយសិស្ស ។<br><br><br><br><br><br><br><br>សិក្ខាកាមបានចូលរួមសំដែងតួ ដើម្បីងាយស្រួល ចងចាំ អំពីវិធីសាស្ត្របានល្អ ។</td><td>១, របៀបបំផុសគំនិត្យស្រាវជ្រាវរកជំនាញ<br>▪ អ្នកសម្របសម្រួលពន្យល់សិក្ខាកាមថា សារសំខាននៃកម្មវិធីបំណិនជីវិតគឺផ្តល់ឳកាស អោយសិស្សធ្វើការសិក្សាស្រាវជ្រាវរកមុខជំនាញពីសហគមន៏ដោយខ្លួនឯង ។ យើងនិងធ្វើការបង្ហាញ អំពីការរៀបចំសិស្សចុះស្រាវជ្រាវ និង វិធីសាស្ត្រ ។អ្នកសម្របសម្រួលសម្តែងធ្វើជាគ្រូចំណែកឯសិក្ខាកាមសម្តែងធ្វើជាសិស្សទាំងអស់គ្នា<br>▪ អ្នកសម្របសម្រួលបែងចែកឯកសារទី៤ ការណែនាំអំពីវិធីសាស្ត្រ និង ការរៀបចំសិស្សចុះស្រាវជ្រាវឱ្យសិក្ខាកាមអាន ១៥ នាទី ហើយធ្វើការដឹកនាំសម្តែងតាមលំនាំបង្រៀនឯកសារចែកទី៤ ដែលបានចែករួចហើយ ។<br>២, ថ្នាក់និទស្សន៏ និង ការសំដែងតួះ<br>▪ អ្នកសម្របសម្រួលចែកឯកសារទី៥ ឱ្យសិក្ខាកាមអាន១៥នាទីមុនការសំដែង ។ រើសសិក្ខាកាមស្ម័គ័ចិត្ត២នាក់អោយឡើង សម្តែងតួ ម្នាក់សម្តែងជាសិស្ស និង ម្នាក់ទៀតសម្តែងជាប្រជាជន ។<br><u>កំណត់សំគាល់</u><br><br>កំណត់សំគាល់<br>▪ ជាការល្អមុននឹងចុះសម្ភាសតាមផ្ទះ ក្រុមអ្នកស្រាវជ្រាវត្រូវព្យាយាមជួបជាមួយក្រុមចាស់ទុំនៅ ក្នុងភូមិ ដើម្បីធ្វើការ ពន្យល់គាត់ពីគោលបំណង និង សុំការណែនាំទាក់ទងនឹងចំណេះដឹងផ្សេងៗដែលអាចចាត់ចូលជា បំណិនជីវិតទូទៅ និង បំណិនជីវិតវប្បធមិដែលមាន នៅក្នុងសហគមន៏នេះ ។<br>▪ ចំពោះ បំណិនជីវិតវប្បធមិ គួរសុំយោបល់ពីក្រុមនេះនូវអ្វីដែលពួកគាត់ចង់ដាក់ចូលក្នុងកម្មវិធី សិក្សា តាមសាលា ។<br>▪ ក្រុមសម្ភាសធ្វើការកត់ត្រាគោលដៅដែលត្រូវចុះសម្ភាស និង ចុះសម្ភាសបន្ត ។</td><td>1- អានឯកសារ<br>2- សួរ- ឆ្លើយ<br>3- ពិភាក្សា<br><br><br><br><br><br><br><br><br>ចូលរួមឆ្លើយសំណួរ និង សំដែងតួ</td></tr>
</table>

<table>
<tr><td>មេរៀន និងការសង្ខេប<br><br>រយៈពេល</td><td colspan="2">៤- ការកំណត់មុខជំនាញ និង គ្រូបំណិនជីវិតពិសហគមន៏ ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពីវិធីសាស្ត្រផ្សេងៗដើម្បីប្រមូលពតិមានពីសិស្សក្រោយពីចុះស្រាវជ្រាវ និងការ បំពេញតារាង ។<br>៩០ នាទី</td></tr>
<tr><td>សម្ភារះប្រើប្រាស់</td><td colspan="2">1- ក្រដាសផ្ទាំងធំ<br>២- ឯកសារចែកទី ៦</td></tr>
<tr><td>វត្ថុបំណង</td><td>សកម្មភាពអ្នកសម្របសម្រួល</td><td>សក្មភាពអ្នកចូលរួម</td></tr>
<tr><td>▪ សិក្ខាកាមអាចរៀបរាប់ពីសកម្មភាពត្រូវធ្វើ ។<br>▪ សិក្ខាកាមទៅដឹកនាំសិស្សប្រមូលពតិមានក្រោយពីការធ្វើការស្រាវជ្រាវ ។</td><td>▪ អ្នកសម្របសម្រួលសួរថា:ឥឡូវសិស្សបានធ្វើការស្រាវជ្រាវរួច ហើយតើយើងត្រូវធ្វើអ្វី ?<br>▪ អ្នកសម្របសម្រួលប្រាប់ថា:យើងនឹងបន្តធ្វើសំដែងបង្ហាញពីរបៀបប្រមូលពតិមានពីសិស្ស ដោយទុកឳកាសឱ្យសិស្សជ្រើសរើសមុខជំនាញសមស្របបំផុតសំរាប់គេដែលប្រមូលបានពីសហគមន៏ អ្នកសម្របសម្រួលធ្វើការបញ្ជាក់ថាជំនាញមួយចំនួនមិនសមស្របទេ ។ ជំនាញដែលរើសយកគួតែមានលក្ខណ:ដូចខាងក្រោម<br><br><u>លក្ខណៈវិនិច្ឆ័យដើម្បីកំនត់ភាពសមស្របនៃសកម្មភាព</u><br>- ជាជំនាញដែលអាចអនុវត្តដោយសុវត្ថិភាព ហើយនិងមិនចាំបាច់មានការត្រួតពិនិត្យខ្លាំងពីមនុស្សពេញវ័យ ។<br>- ជាជំនាញក្នុងបញ្ជីជំនាញ រៀបចំដោយសិស្សក្រោយពីចុះស្រាវជ្រាវ ។<br>- យ៉ាងហោចណាស់មានកុមារ ៥នាក់ដែលចង់រៀនជំនាញនេះ ។<br>- មានមនុស្សក្នុងសហគមន៏ដែលអាចបង្រៀនជំនាញនេះបាន ។<br>- ជាជំនាញដែលសិស្សបឋមសិក្សាអាចអនុវត្តស្របច្បាប់ ។<br>- តំលៃនៃការអនុវត្តមិនលើសពីថវិកាដែលមាន ។<br>- មិនបះពាល់ដល់សុខភាពកុមារ ។<br><br>▪ អ្នកសម្របសម្រួលបែងចែកឯកសារចែកទី៦ ។ ហើយពន្យល់ថាការសំដែងនេះ អ្នកសម្របសម្រួល ដើរតួជាគ្រូបង្រៀនថ្នាក់ ទី ៥ -៦ ហើយអ្នកចូលរួមដើរ តួជាសិស្សថ្នាក់ទី៥-៦ ។<br>▪ អ្នកសម្របសម្រួលបែងចែក តារាង"ក"ស្រាវជ្រាវឱ្យអ្នកចូលរួមដែលតារាងនោះត្រូវបានបំពេញក្នុងពេលធ្វើបង្ហាញលើកមុន ។<br>▪ អ្នកសម្របសម្រួលសួរសិក្ខាកាមដើម្បីបញ្ជាក់ច្បាស់ពីកូឡោននីមួយៗថា អ្វីខ្លះដែល យើងត្រូវបំពេញបញ្ចូល?<br>ត្រូវទុកពេលឱ្យសិក្ខាកាមសួរ ករណីមិនទាន់ច្បាស់ ។<br>▪ អ្នកសម្របសម្រួលដឹកនាំដំណើរការសម្តែងតាម ឯកសារចែកទី៦</td><td>▪ អ្នកចូលរួមឆ្លើយថា:ប្រមូលពតិមានពីសិស្ស ។<br><br>▪ ចូលរួមឆ្លើយ- សួរ<br>▪ សំដែងតួ<br>▪ អ្នកចូលរួមជួយបំពេញតារាង អោយបាន៉្យងតិច១០ជំនាញ</td></tr>
</table>

| មេរៀន និងការសង្ខេប | ៥- ការប្រជុំតម្រង់ទិសលើកទី១ ដល់ គ្រូបំណិនជីវិត និង មាតាបិតាសិស្ស<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី របៀបដឹកនាំធ្វើការប្រជុំលើកទី១ ជាមួយគ្រូបំណិនជីវិតដែលសិស្សទើបបានជ្រើសរើស និង មាតាបិតាសិស្ស។ | |
|---|---|---|
| រយៈពេល | ៣០ នាទី | |
| សម្ភារៈប្រើប្រាស់ | ១- ឯកសារចែក ៧ | |
| វត្ថុបំណង | សកម្មភាពអ្នកសម្របសម្រួល | សកម្មភាពអ្នកចូលរួម |
| 1- សិក្ខាកាមអាចរៀបរាប់ពីសកម្មភាព។<br>2- សិក្ខាកាមអាចធ្វើបានផែនការ | ▪ អ្នកសម្របសម្រួលធ្វើការពន្យល់ថា វាជារឿងសំខាន់ណាស់ក្នុងការកោះប្រជុំលើកទី១ ជាមួយគ្រូបំណិនជីវិតដែល សិស្សទើបបានជ្រើសរើស និង មាតាបិតាសិស្ស ដើម្បីធ្វើការពន្យល់ពួកគាត់ពីគោលបំណងនៃកម្មវិធី<br>អញ្ជើញពួកគាត់អោយមកមើលសកម្មភាពសិក្សារបស់កូន( ចំពោះ មាតាបិតាសិស្ស ) និង បញ្ជាក់ជាមួយគ្រូបំណិនជីវិតដែលត្រូវបានជ្រើសយកពី ចំនួនក្រុមដែលត្រូវបង្រៀន និង ពេលវេលាបង្រៀន ឯកភាពលើប្រាក់ឧបត្ថម្ភ និង ធ្វើកិច្ចសន្យាជាមួយគាត់។<br><br>▪ អ្នកសម្របសម្រួលចែកឯកសារចែកទី៧ ធ្វើការណែនាំពីលំនាំសម្របសម្រួលការប្រជុំ តាមឯកសារ។<br><br>▪ អ្នកសម្របសម្រួលចែកកិច្ចសន្យា **ឯកសារចែកទី ៨** អោយគ្រូបំណិនជីវិតរួចធ្វើកាពន្យល់គាត់ដោយអានឱ្យគាត់ស្តាប់១មាត្រាម្តង១ ហើយសួរគាត់ថាឯកភាពឬទេ ? ឬមានត្រង់ណាអាចកែតម្រូវ? ។<br>▪ គ្រូបំណិនជីវិតម្នាក់ៗធ្វើការពិនិត្យ និង ចុះហត្ថលេខា លើកិច្ចសន្យា<br>▪ អ្នកសម្របសម្រួលប្រមូលឯកសារទាំងនោះទុករួចកំណត់ពេលវេលាជួបជាមួយគ្រូបំណិនជីវិតមួយលើកទៀតដើម្បីធ្វើផែនការមេរៀន និង ផែនការបង្រៀន។ | 1- អាន<br>2- ចូលរួមឆ្លើយ<br>3 - សួរ<br>4- ពិភាក្សា<br>5- ធ្វើផែនការ |

| | | |
|---|---|---|
| មេរៀន និងការសង្ខេប<br><br><br>រយៈពេល | **៦- ការធ្វើផែនការមេរៀន :**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី របៀបធ្វើផែនការមេរៀន និង កំណត់ពីសម្ភារត្រូវការចាំបាច់សំរាប់ការបង្រៀន ។<br>៦០ នាទី | |
| **សម្ភារះប្រើប្រាស់** | 1- ក្រដាសផ្ទាំងធំ<br>2- ឯកសារចែកទី ៩ | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សក្មភាពអ្នកចូលរួម** |
| 1- សិក្ខាកាមអាចដឹកនាំគ្រូធ្វើមេរៀនបំណិនជីវិតសំរាប់បង្រៀនរយៈពេល ១០ សប្តាហ៍ ។ | ▪ អ្នកសម្របសម្រួលពន្យល់ថា យើងត្រូវធ្វើការពិភាក្សាជាមួយគ្រូបំណិនជីវិតជាមុនសិនព្រោះអាចថាគាត់មិនដែលមានបទពិសោធន៏ បង្រៀន ហើយគ្រូខ្លះគាត់មិនចេះអក្សរទៀតផង ។ ដូច្នេះទាមទា ការជួយគាំទ្រពីគ្រូថ្នាក់ទី៥ ទី៦ដើម្បីធ្វើការរួមគ្នាក្នុងការរៀបចំ មេរៀន ។<br><br>▪ អ្នកសម្របសម្រួលចែកឯកសារចែកទី៩ ធ្វើការណែនាំពីលំនាំសម្របសម្រួលការប្រជុំ ធ្វើផែនការមេរៀនតាមឯកសារ ។ | |



| | | |
|---|---|---|
| មេរៀន និងការសង្ខេប<br><br><br>រយៈពេល | **៧- ការកំណត់ថវិការៈ**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី របៀបធ្វើការកំណត់ថវិការសំរាប់មុខជំនាញនីមួយៗ ។<br><br>៦០ នាទី | |
| **សម្ភារះប្រើប្រាស់** | 1- ក្រដាសផ្ទាំងធំ<br>2- ឯកសារចែកទី ១០ | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សក្មភាពអ្នកចូលរួម** |
| 1- សិក្ខាកាមអាចកំណត់បានពីថវិការសំរាប់ជំនាញនីមួយៗ ។ | ▪ អ្នកសម្របសម្រួលពន្យល់ថា តាមផែនការកែលំអរកម្រងសាលារៀន ដែលបានឯកភាពគ្នារួចមកហើយ យើងកំណត់ថា: ថវិការ ៣៥០ ដុល្លា សម្រាប់បំណិនជីវិតទូទៅនៅក្នុង១សាលា ដែលមានយ៉ាងតិច ១៨ ក្រុមបំណិនជីវិត និង ៥០ ដុល្លា សម្រាប់បំណិនជីវិតទាក់ទងនិងវប្បធម៌ ។<br>▪ តាមការអនុវត្តជាក់ស្តែងសម្រាប់ខេត្ត ក្រចេះ និង មណ្ឌលគីរី ប្រសិនបើយើងរើសយកថ្នាក់ទី៥មួយថ្នាក់ និងថ្នាក់ទី៦មួយថ្នាក់យើងនឹងមិនអាចមាន ក្រុមបំណិនជីវិតច្រើនរហូតដល់ | 1- អាន<br>2- ចូលរួមឆ្លើយ<br>3 - សួរ<br>4- ពិភាក្សា |

| | | |
|---|---|---|
| | ១៨ក្រុមនោះទេ ដូចនេះយើងអាចសន្សំថវិកាពីបំណិនជីវិតទូទៅខ្លះមកប្រើលើបំណិនជីវិតទាក់ទងនិងវប្បធម៌ ។<br><br>▪ អ្នកសម្របសម្រួលចែកឯកសារចែកទី១០ ធ្វើការណែនាំពីលំនាំ សម្របសម្រួលការប្រជុំ ធ្វើការកំណត់ថវិកាតាមឯកសារចែកទី១០ ។ | |

9

| | | |
|---|---|---|
| មេរៀន និងការសង្ខេប<br><br>រយៈពេល | **៨- ការធ្វើផែនការសកម្មភាព :**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមអំពី របៀបធ្វើផែនការសកម្មភាព សំរាប់ការបង្រៀនបំណិន ជីវិត ។<br><br>១៥ នាទី | |
| សម្ភារះប្រើប្រាស់ | 1- ក្រដាសផ្ទាំងធំ<br>2- ឯកសារចែកទី ១១ | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| ▪ សិក្ខាកាមដែលតំណាងអោយសាលានីមួយៗធ្វើផែន កាអនុវត្តជាក់ស្តែងច្បាស់លាស់សំរាប់យកទៅអនុវត្ត ។ | ▪ អ្នកសម្របសម្រួល ស្នើអោយសិក្ខាកាមដែលមកពីសាលាជាមួយគ្នាអង្គុយជិតគ្នាដើម្បីងាយស្រួលក្នុងការពិភាក្សា ។<br>▪ អ្នកសម្របសម្រួល ចែកតារាងផែនការសកម្មភាពដល់សិក្ខាកាម ទាំងអស់ ។<br>អ្នកសម្របសម្រួល ធ្វើការពន្យល់ ពីរបៀបបំពេញតារាង ។ | ▪ ពិភាក្សាគ្នាបំពេញតារាងផែន ការ ។ |

| | | |
|---|---|---|
| មេរៀន និងការសង្ខេប<br><br>រយៈពេល | **៩- ការតាមដាន និងវាយតម្លៃ:**<br>ផ្នែកនេះបានបង្ហាញដល់សិក្ខាកាមឱ្យបានច្បាស់ថា រាល់ការអនុវត្តត្រូវតែមានការតាមដានដើម្បីធានាថា ការអនុវត្តនោះ ទទួលបាននូវលទ្ធផលកំរិតណា និងធ្វើសេចក្តីសម្រេចចិត្តថាអ្វីត្រូវកែលំអឈានដល់ការទទួលបានជោជ័យ ។<br>៦០ នាទី | |
| សម្ភារះប្រើប្រាស់ | 1- ក្រដាសផ្ទាំងធំ<br>2- ហ្វឺត<br>3- ឯកសារចែក ១២ | |
| **វត្ថុបំណង** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| 1- សិក្ខាកាមអាចរៀប | **អ្នកសម្របសម្រួលចាប់ផ្តើមសួរក្រុមធំថា:** | 1- អាន |

| | | |
|---|---|---|
| រាប់ពីនិយមន័យ។<br>2- សិក្ខាកាមអាចរៀបរាប់ពី សារៈសំខាន់។<br>3- សិក្ខាកាមអាចបំពេញតារាងតាមដាន។ | 1- តើការតាមដានមានន័យយ៉ាងដូចម្ដេច? ស្ដាប់ចម្លើយ និងកត់ត្រាលើក្ដារខៀន បូកសរុប ហើយបិទក្រដាសផ្ទាំងធំលើក្ដារខៀនដើម្បីចូលរួមចម្លើយ។<br>2- ហេតុអ្វីយើងធ្វើការតាមដាន? ស្ដាប់ចម្លើយ និងកត់ត្រាលើក្ដារខៀន បូកសរុប ហើយបិទ ក្រដាសផ្ទាំងធំលើក្ដារខៀនដើម្បីចូលរួមចម្លើយ។<br>3- តើអ្នកធ្លាប់ធ្វើការតាមដាន វាយតម្លៃដែរឬទេ? បើធ្លាប់ធ្វើដោយរបៀបណា? ចែកក្រុមពិភាក្សា។<br>4- ឱ្យសិក្ខាកាមឡើងរាយការណ៍តាមក្រុម បូកសរុបចម្លើយ និងចែកឯកសារមេរៀន។ | 2- ចូលរួមឆ្លើយ<br>3 - សួរ<br>4- ពិភាក្សា<br>5- ធ្វើផែនការ |

អង្គការអប់រំពិភពលោក
WORLD EDUCATION

## កម្មវិធីគាំទ្រវិស័យអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

(អេឃ្វាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# ឯកសារសម្រាប់អ្នកចូលរួម

## វគ្គតម្រង់ទិសស្តីពីបំណិនជីវិត

សម្រាប់

## សមាជិកក្រុមទទួល, នាយក, គ្រូ និង តំណាងសហគមន៍

ខែមករា ឆ្នាំ២០០៧

**ឯកសារចែកទី ១**

# គោលបំណង គោលដៅ និង លទ្ធផលរំពឹងទុក នៃ សិក្ខាសាលា

**គោលបំណង (Purpose) :**

គោលបំណងនៃអង្គសិក្ខាសាលានេះគឺដើម្បីកសាងសមត្ថភាពសមាជិកក្រុមចំបងទទួល បន្ទុកការងារបំណិន ជីវិត និង ក្រុមគាំទ្រសកម្មភាពបំណិនជីវិតប្រចាំសាលា អោយគេអាចដាក់ចេញនូវផែនការអនុវត្ត សកម្មភាព បំណិន ជីវិត និង មានលទ្ធភាពសម្របសម្រួលដំណើរការអនុវត្តសកម្មភាពបំណិនជីវិតនៅតាមសាលារៀនរៀងៗខ្លួន។ សិក្ខាកាមទាំងអស់ និងទទួលបាន នូវការហ្វឹកហ្វឺនរយៈពេលពេញមួយថ្ងៃ ដែលនឹងផ្តោតជាសំខាន់លើគោលការណ៍ ជាមូលដ្ឋាន នៃកម្មវិធីបំណិនជីវិត,ការរៀបចំក្រុម,ការស្រាវជ្រាវរកជំនាញ, និង ការអនុវត្តសកម្មភាព ជាក់ស្តែង។

**គោលដៅ (Objective) :**

សិក្ខាសាលានេះមានគោលដៅដូចខាងក្រោម

១, សិក្ខាកាមទាំងអស់យល់បានច្បាស់ពី គោលការណ៍ជាមូលដ្ឋាន នៃកម្មវិធីបំណិនជីវិត

២, សិក្ខាកាមទាំងអស់អាចយកចំណេះដឹងដែលទទួលបានពីសិក្ខាសាលានេះទៅអនុវត្តជាក់ស្តែងនៅតាម សាលា រៀងៗខ្លួន។

**លទ្ធផលរំពឹងទុក (Products from workshop) :**

សិក្ខាសាលានេះនឹងឈានទៅបង្កើតលទ្ធផលមួយចំនួនដូចខាងក្រោមៈ

១, បង្កើតផែនការសំរាប់អនុវត្តសកម្មភាពជាកស្តែងសកម្មភាពបំណិនជីវិតនៅតាមសាលានីមួយៗ

២, កំណត់អ្នកទទួលខុសត្រូវសកម្មភាពបំណិនជីវិតនៅតាមសាលានីមួយៗ និង សមាជិកក្រុមចំបង ទទួលបន្ទុក ការងារបំណិនជីវិតនៅតាមកំរង។

ឯកសារចែកទី ២

# កម្មវិធីបំណិនជីវិត

## ក/ គោលបំណងនៃកម្មវិធីបំណិនជីវិត

1. អនុវត្តសកម្មភាពបន្ថែមលើកម្មវិធីសិក្សាផ្លូវការក្រៅម៉ោង ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារ ហើយនឹងជីវភាពរស់នៅ ជាក់ស្តែងរបស់គេ ។
2. ផ្តល់ឱកាសអោយកុមារធ្វើការសំរេចចិត្តជ្រើសរើសនូវអ្វីដែលគេចង់រៀន ។
3. ពង្រឹងទំនាក់ទំនងស្និទស្នាលរវាងសាលា និង សហគមន៍ ព្រមទាំងផ្តល់ឱកាសអោយសហគមន៍ ចូលរួមក្នុងការរៀនសូត្ររបស់កុមារ ។

## ខ/ ក្រុមគោលដៅ

- គ្រប់សាលារៀនដែល អេស្កាប់គាំទ្រ ហើយបានលើកផែនការសំរាប់បំណិនជីវិតទូទៅ និងបំណិនជីវិត ទាក់ទងនឹងវប្បធម៌ ។
- សាលាគួរតែជ្រើសរើសថ្នាក់ទី ៥ មួយថ្នាក់ និង ថ្នាក់ទី ៦ មួយថ្នាក់[១] មកអនុវត្តកម្មវិធីនេះដោយជ្រើសរើសយកមុខវិជ្ជា យ៉ាងច្រើនត្រឹមតែ ពីរសំរាប់បំណិនជីវិតនីមួយៗ ( គឺបំណិនជីវិតទូទៅ ២ មុខវិជ្ជា និងបំណិនជីវិតទាក់ទង នឹងវប្បធម៌២ មុខវិជ្ជា ។ ដើម្បីងាយស្រួលក្នុងការពង្រឹង សមត្ថភាពរបស់គ្រូ នាយកសាលា ហើយនិងសមាជិកសហគមន៍ ។
- សិស្សថ្នាក់ទី៥ និងទី៦ដែលបានស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាពបន្ថែមលើកម្មវិធីសិក្សាផ្លូវការ ក្រៅម៉ោង ។

## គ/ សារៈសំខាន់ក្នុងការរៀបចំកម្មវិធីបំណិនជីវិត

1. សិស្សនឹងធ្វើការស្រាវជ្រាវដោយខ្លួនឯងដើម្បីស្គាល់ជំនាញ និង ធនធានមនុស្សដែលមានក្នុង សហគមន៍របស់ខ្លួន ។
2. សិស្សអាចជ្រើសរើសជំនាញមួយដែលគេចង់រៀន ដកស្រង់ចេញពីបញ្ជីជំនាញដែលស្រាវជ្រាវ រកឃើញពីក្នុងសហគមន៍ [២] ។
3. សិស្សអាចជ្រើសរើសមនុស្សម្នាក់ពីសហគមន៍ដែលអាចធ្វើជាគ្រូសំរាប់មកបង្រៀនដល់ពួកគេ ។
4. កុមារនឹងសិក្សាជំនាញដែលគេបានជ្រើសរើសតាមក្រុមរបស់ខ្លួនដែលមានគ្នាពី ៤ -៥ នាក់ រៀងរាល់ ថ្ងៃព្រហស្បតិ៍ រយៈពេល ១ ម៉ោង រយៈពេល ១០ សប្តាហ៍ ។
5. សមាជិកម្នាក់ក្នុង ក្រុមចម្បងប្រចាំកម្រងសាលា ទទួលបន្ទុកកម្មវិធីបំណិនជីវិតត្រូវចុះ ត្រួតពិនិត្យ សកម្មភាពបង្រៀន របស់ គ្រូសហគមន៍រៀងរាល់ថ្ងៃព្រហស្បតិ៍ ឬ ថ្ងៃអាទិត្យ

---

១ ដោយឡែកសំរាប់សាលានៅតាមជនបទដែលសិស្សថ្នាក់ទី ៥ និង ទី៦មានចំនួនតិច យើងអាចបន្ថែមថ្នាក់បាន ។

២ ប្រសិនជាការជ្រើសរើសទីមួយរបស់កុមារមិនអាចបង្រៀនបានដោយសារគ្មានកុមារផ្សេងទៀតបានជ្រើសរើសជំនាញនេះកុមារអាចជ្រើសរើសម្តងទៀតនូវមុខ ជំនាញដែលមានក្នុងបញ្ជីជាចុងក្រោយ ។

ឯកសារចែកទី ៣

# ដំណើរការកម្មវិធីបំណិនជីវិត

1. អ្នកសម្របសម្រួលកម្មវិធីអេស្កាប់ ប្រចាំខេត្តនីមួយៗធ្វើការពិភាក្សាជាមួយប្រធានកំរង និង សមាជិកក្រុមចំបងទទួលបន្ទុកកម្មវិធីបំណិនជីវិតដើម្បីធ្វើការពិភាក្សាបន្តជាមួយនាយកសាលានៅក្នុងកំរងរបស់ខ្លួនដែលបានដាក់បញ្ចូលកម្មវិធីបំណិនជីវិតនៅក្នុងផែនការដើម្បីកំណត់ពីថ្នាក់ទី៥មួយថ្នាក់ និង ទី៦ មួយថ្នាក់ ដែលត្រូវជ្រើសរើសព្រមទាំងគ្រូប្រចាំថ្នាក់ទាំងនោះផង។ រៀបចំលិខិតអញ្ជើញស្តីអំពីការតម្រង់ទិសកម្មវិធីបំណិនជីវិតផ្ញើទៅគ្រូ ថ្នាក់ទី៥មួយថ្នាក់ និង ទី៦ មួយថ្នាក់ ដែលបានជ្រើសរើសនោះ, នាយកសាលា , និងតំណាង សហគមន៍។

2. រៀបចំតំរង់ទិសសំរាប់គ្រូថ្នាក់ទី ៥ ,៦, នាយកសាលា សមាជិកក្រុមចំបង និង តំណាងសហគមន៍។ តំរង់ទិសនេះ និង បង្ហាញថ្នាក់និទស្សន៍ ( ដោយប្រើសិស្សជាក់ស្តែង ) អំពីវិធីរៀបចំសិស្សធ្វើការស្រាវជ្រាវ។

3. គ្រូ ទី ៥ ,៦,បន្ទាប់ពីបានចូលរួមតំរង់ទិសលើកទី១ ត្រូវរៀបចំតំរង់ទិសរួមគ្នាដល់សិស្សទាំងពីរថ្នាក់ដែលត្រូវជ្រើសរើស និង ធ្វើការបែងចែកក្រុមសិស្សសំរាប់ធ្វើការស្រាវជ្រាវ (ចូរមើលឯកសារ ណែនាំពីរបៀបចុះស្រាវជ្រាវ)

4. សិស្ស ចុះស្រាវជ្រាវអំពីជំនាញ និង ធនធាន មនុស្សដែលមានក្នុងសហគមន៍ ។

5. គ្រូនឹងជួយសិស្សរៀបចំ និង បង្ហាញពតិមាន។ សិស្សនឹងរៀបចំខ្លួនជាក្រុមតូចៗ ( មួយក្រុម ៥ នាក់) តាមជំនាញដែលគេចង់រៀន ។ ម្យ៉ាងទៀតសិស្សនឹងកំនត់មនុស្សពីសហគមន៍ដែលគេសុំអោយបង្រៀន។

6. សាលានីមួយៗគួរតែផ្ញើពតិមានទាំងអស់នេះដល់សមាជិកក្រុមចំបង និង ក្រុមការងារកម្មវិធី អេស្កាប់ប្រចាំខេត្ត ។ បុគ្គលិក វី ក្រុមការងារ និង ជួយគណៈកម្មការកំរងសាលារៀបចំថវិកាចំណាយបណ្តោះអាសន្ន ។

7. បន្ទាប់មកក្រុមចំបងត្រូវតែរៀបចំសំបុត្រអញ្ជើញសំរាប់តំរង់ទិសផ្ញើដល់អ្នកដែលត្រូវបាន ជ្រើសរើសជាគ្រូបំណិនជីវិត និង មាតាបិតាសិស្ស ដើម្បីធ្វើការតំរង់ទិស។ ការតំរង់ទិសនេះ សង្កត់ធ្ងន់លើការពន្យល់មូលហេតុ និង គោលបំនងនៃកម្មវិធី ។ ម្យ៉ាងទៀត ក្រុមចំបង និង គ្រូសហគមន៍ នឹងឯកភាពគ្នាអំពី ប្រាក់ ឧបត្ថម្ភសំរាប់គ្រូបំណិនជីវិតកាលបរិច្ឆេទ និង ពេលវេលាហើយនិងថវិកាដែលអាចប្រើទិញសំភារៈនឹងអាចអញ្ជើញ មាតា បិតាសិស្ស អោយមកមើលសកម្មភាពកូនរបស់ខ្លួនបាន ពីរសប្តាហ៍ក្រោយពីចាប់ផ្តើមរៀន ។

8. អ្នកភូមិដែលយល់ព្រម ធ្វើគ្រូបំណិនជីវិតចូលរួមរៀបចំផែនការមេរៀនជាមួយក្រុមចំបង ។សិក្ខាសាលានេះមានគោលបំណងផ្សំ ឯកទេសរបស់គ្រូសហគមន៍ជាមួយឯកទេស និង បទពិសោធន៍របស់គ្រូបឋមសិក្សាចំពោះការរៀនសូត្ររបស់កុមារ ។ គ្រូបឋមសិក្សាជួយអោយ គ្រូបំណិនជីវិតវិភាគជំហាននីមួយៗក្នុងការអនុវត្តន៍ជំនាញ រួចមកគ្រូបឋមសិក្សាជួយគ្រូរៀបចំ មេរៀន សំរាប់សប្តាហ៍នីមួយៗ។

ឯកសារចែក ៤

# ការតម្រង់ទិសដល់សិស្សថ្នាក់ទី៥ និង ទី៦អំពី
# វិធីបំផុសរកជំនាញ និង រៀបចំសិស្សចុះស្រាវជ្រាវ

១, , ការរៀបចំក្រុមសិស្សចុះស្រាវជ្រាវៈ

គ្រូធ្វើការពន្យល់ពីគោលបំណងនៃកម្មវិធីបំណិនជីវិតដោយ

ផ្អែកលើ **ឯកសារចែកទី ២**

ក-គ្រូកំណត់សិស្សដែលស្ម័គ្រចិត្ត : ដោយសួរទៅសិស្សថា:

តើប្អូនៗណាខ្លះដែលស្ម័គ្រចិត្តចូលរួមជាមួយកម្មវិធីបំណិវជីវិត ដើរទេ?

> ឆ្នាំទី១សាលាគួរកំណត់សិស្សមិនឱ្យលើស ពី ១០០នាក់ ទេ ហើយជំនាញក៏មិនគួរ លើសពី២ សំរាប់ បំណិនជីវិតនីមួយៗ) ។

ខ-ការបែងចែកសិស្សតាមភូមិ : គ្រូសួរសិស្សម្នាក់ឈ្មោះ(ក)ថា តើប្អូនរស់នៅភូមិណា? សិស្សឆ្លើយថា ខ្ញុំនៅ ភូមិ(ថ្មី) គ្រូប្រាប់សិស្សដ៏ទៃថា ប្អូនណានៅភូមិថ្មីខ្លះមកឈរម្តុំ។ គ្រូសួរបែបនេះរហូត អស់ចំនួនសិស្ស ។

គ-ការបែងចែកសិស្សជាក្រុមចុះស្រាវជ្រាវតាមភូមិៈ គ្រូបែងចែកសិស្សតាមភូមិនីមួយៗជាក្រុមមិនឱ្យលើស ពី៥នាក់ ករណីភូមិណាមួយមានសិស្សតិចជាង៥នាក់ ត្រូវឱ្យសិស្សដែលមកពីភូមិជិតខាងដែលមានចំនួនសិស្សលើស៥នាក់ចូលមកបង្គ្រប់ ។ ចំណែកឯភូមិណាដែលមានចំនួនសិស្សច្រើនជាង៥នាក់គ្រូត្រូវបែងចែកជាក្រុមតូចៗសម្រាប់ចុះធ្វើការស្រាវជ្រាវ ។

**២- ការបំផុសរកជំនាញៈ**

ក- គ្រូសួរសិស្សនូវសំណួរដូចខាងក្រោម

- អ្នកភូមិរបស់ប្អូនៗ គេប្រកបមុខរបរអ្វីខ្លះដើម្បីចិញ្ចឹមជីវិត? ចម្លើយ ..............................

ករណីសិស្សមិនទាន់យល់ គ្រូបំផុសថា បើកង់ខូច ចង់កាត់ខោអាវ ចង់កាត់សក់ ឬអ៊ុតសក់ ចង់បានឧបករណ៍នេសាទ ត្រូវការជួសជុលឧបករណ៍កសិកម្ម, ប្អូនទៅណា?

- អ្នកភូមិរបស់ប្អូនៗ មានជនជាតិអ្វីខ្លះរស់នៅ ? ចម្លើយ .............................. តើមានទំនៀមទំលាប់ ប្រពៃណី របៀបរបបរស់នៅ សិល្បៈ ភាសា ។ល ។ ដែលគួរជាទីចាប់អារម្មណ៏សំរាប់ប្អូនចង់សិក្សា ករណីសិស្សមិនទាន់យល់ គ្រូបំផុសថា ដូចជាភ្លេង, របាំ, ល្បែងប្រជាប្រិយ៏, កីឡា, គំនូរ ,ភាសា, ។ល ។

( គ្រូអាចអោយសិស្សឆ្លើយ រឺ សរសេរលើក្រដាស់កាតក៏បាន )

ខ- គ្រូកត់ចម្លើយសិស្សរហូតបានច្រើនជាង២០មុខជំនាញ លើក្តារខៀនទើបទុកពេល៥នាទី ឱ្យសិស្សកត់ចូលក្នុង សៀវភៅរបស់ពួកគេ។(សូមព្យាយាមទុកពេលឱ្យសិស្សឆ្លើយ ជៀសវាងធ្វើជំនួស)

គ- គ្រូដឹកនាំកូនសិស្សធ្វើការវិភាគទៅលើចម្លើយតើមុខជំនាញណាមួយជាបំណិនជីវិតទូទៅ និង ណាមួយជាបំណិន ជីវិតទាក់ទងនិងវប្បធម៌ ។ គ្រូសរសេរចម្លើយលើក្តារខៀន

ប្រសិនបើសិស្សមិនអាចរកនឹកឃើញ គ្រូត្រូវពន្យលថា ពាក្យថាវប្បធម៏គឺយើងផ្តោតទៅលើទិដ្ឋភាពដូចជា:

| | |
|---|---|
| - ភាសា | - ការរាំ ច្រៀង |
| - សិល្បៈ | - កំណាព្យ |
| - ការចំអិនម្ហូប, | - ល្បែងប្រជាប្រិយ, |
| - កីឡា | - ការនិទានរឿង |

ចម្លើយរំពឹងទុក

**បំណិនជីវិតវប្បធម៌**

- ប្រើឧបករណ៍ភ្លេងបុរាណ
- របាំ ខ្មែរ, ជនជាតិ
- របៀបគោរពប្រតិបត្ត
- ភាសា
- ការរៀបចំអាហារ
- ការផលិតឧបករណ៍ភ្លេង
- ចំលាក់ គំនូរ
- ល្បែងប្រជាប្រិយ
- កីឡា
- ការផ្សំឱសថបុរាណ
- ។ល។

**បំណិនជីវិតទូទៅ**

- ការជួសជុលកង់
- ការបំប៉ៅ ផ្សាំ កូនឈើ
- ការលក់ដូរក្នុងផ្សារ
- ការធ្វើនំ
- សំអាងការ
- ការធ្វើស្ករ
- ការផលិតឧបករណ៍ប្រើប្រាស់( ប្រចាំថ្ងៃ,នេសាទ,កសិកម្ម ។ល។)
- វិធីសង្គ្រោះបន្ទាន់
- កាត់ដេរ , ដំបាញ
- ជាងដែក
- ជាងកាត់សក់
- ។ល។

ឃ- គ្រូគូរតារាង " ក "ស្រាវជ្រាវលើក្តារខៀន ហើយបំពេញពតិមានដូចឧទាហរណ៍ទី១ ក្នុងតារាងពន្យល់ សិស្សបំពេញ

**តារាង "ក"**

**ស្រាវជ្រាវពីជំនាញទូទៅ និង ជំនាញវប្បធម៌**

ឈ្មោះភូមិ ............................ ឃុំ ....................ស្រុក ...................... ខេត្ត ............................

| ឈ្មោះអ្នកចេះធ្វើជំនាញ | ឈ្មោះជំនាញ | ទីលំនៅឈ្មោះអ្នកចេះធ្វើជំនាញ | រយៈពេលអនុវត្តជំនាញកន្លងមក | ឯកភាពបង្រៀន | |
|---|---|---|---|---|---|
| | | | | ព្រម | មិនព្រម |
| បង ធួន | ជួសជុលកង់ | ភូមិចារ ខាងកើតរបងវត្ត សំបួរ | ១០ ឆ្នាំ | ព្រម | |
| ពូ សេន | ជួសជុលកង់ | ភូមិចារ ជិតផ្ទះប្រធានភូមិ | ៨ ឆ្នាំ | ព្រម | |
| ពូ ចេង | ជួសជុលកង់ | កែងផ្លូវចូលភូមិចារ | ១៣ ឆ្នាំ | | |
| | អ៊ុតសក់ | | | | |
| | អ៊ុតសក់ | | | | |
| | អ៊ុតសក់ | | | | |
| | | | | | |
| | | | | | |

ឃ- គ្រូឱ្យសិស្សម្នាក់ឡើងក្ដារខៀនចាំបំពេញតារាងតាមចម្លើយសិស្សម្នាក់ទៀត ហើយផ្ដើមសួរសិស្សម្នាក់ទៀតថា:

| | | |
|---|---|---|
| -អ្នកភូមិរបស់ប្អូនគេប្រកបមុខរបរអ្វីខ្លះ? | សិស្សឆ្លើយថា | គាត់ជាជាងកាត់ដេរ......................។ល។ |
| -គាត់មានឈ្មោះអ្វីដែរ ? | .................. | គាត់ឈ្មោះ មីង មុំ |
| -ផ្ទះគាត់នៅឯណា? | .................. | ផ្ទះគាត់នៅភូមិ ថ្មី ជិតប៉ុស្ដិ៍សុខភាពឃុំ ពីន |
| -គាត់ប្រកបមុខរបរនេះប៉ុន្មានឆ្នាំហើយ? | .................. | ៧ ឆ្នាំហើយ |
| -គាត់ព្រមមកបង្រៀននៅសាលាយើងឬទេ? | .................. | ព្រម ។ |

គ្រូធ្វើដូចនេះច្រើនដងអាស្រ័យដោយចំនួនក្រុមសិស្ស ។ ហើយសួរសិស្សបន្តថា តើនៅមានត្រង់ណាដែលពិបាកជាងគេ?

ង-គ្រូចែកតារាងដូចបានបំពេញលើក្ដារខៀនឱ្យសិស្ស ១ក្រុម ១សន្លឹកបំពេញរយៈពេល១០នាទី រួចប្រមូល ។

ច- គ្រូពិនិត្យកិច្ចការរបស់សិស្ស ហើយផ្ដល់ពតិមានត្រឡប់ដល់ក្រុមដែលបំពេញមិនទាន់បានត្រឹមត្រូវ និងធ្វើការបកស្រាយពន្យល់បន្ថែម ។

**៣- ពតិមានស្ដីពីការចុះស្រាវជ្រាវៈ**

ក-គ្រូប្រាប់សិស្សថា ក្រុមនីមួយៗនឹងចុះធ្វើការស្រាវជ្រាវតាមផ្ទះក្នុងភូមិរបស់ប្អូនដើម្បីបំពេញតារាងដែលយើង ទើបបានអនុវត្តមុននេះ។

ខ-គ្រូរៀបចំធ្វើផែនការសកម្មភាពជាមួយសិស្សដោយកំណត់:

-ថ្ងៃត្រូវចុះស្រាវជ្រាវ :............................................

-កំណត់ទីកន្លែង/ ពេលវេលាជួបគ្នា:.................................................

-ការបែងចែកភារកិច្ចក្រុមមាន:

-អ្នកសម្ភាសន៍: ត្រូវចាំស្ទាត់កំរងសំណួរ ព្រោះជាអ្នកសួរ។

-អ្នកកត់ត្រា: គឺត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់មុននឹងអ្នកសម្ភាសន៍ចាប់ផ្ដើមសួរព្រោះចាំតែកត់ចម្លើយ

-អ្នកជំនួយការទូទៅ: ត្រូវតាមដានមើលអ្នកសម្ភាសន៍ និងអ្នកកត់ត្រា បើ មានខ្វះត្រង់ណាមិនទាន់បាន សួរត្រូវជួយរំឭក ហើយបើអ្នកកត់ត្រាមិនទាន់ វិញត្រូវជួយកត់បន្ថែម។

-ថ្ងៃត្រូវប្រមូលលទ្ធផលប្រគល់ឱ្យគ្រូ :............................................ ។

# ថ្នាក់និទស្សន៍/សំដែងតួ

១- គ្រូសួរសិស្សថា តើប្អូនៗត្រូវធ្វើដូចម្តេចខ្លះ នៅពេលជួបជាមួយអ្នកភូមិ ?

- គោរពកិច្ចពេលជួបពួកគាត់ដំបូង?
- ក្នុងពេលកំពុងជួបគាត់?
- ពេលចប់សម្ភាសន៍?

២- ចែកក្រដាសសម្តែងតួឱ្យសិស្សអាន ១០នាទី ដែលមានខ្លឹមសារដូចខាងក្រោម:

-សិស្ស : ជម្រាបសួរ ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/លោកយាយ ។ល ។ )

-ប្រជាជន: លើកដៃថ្វាយព្រះ/ល្អហើយ ( ប្អូន. ក្មួយ. ចៅ ។ល ។ ) តើអ្នកមានកិច្ចការអ្វីដែរ ?

-សិស្ស: បាទ! ពួកខ្ញុំជាសិស្សរៀននៅសាលា........ .....ហើយសាលាមានកម្មវិធីមួយ ដែលជួយឧបត្ថម្ភ ដោយគម្រោង អេស្កាប់នៃ អង្គការអប់រំពិភពលោក ហៅថាកម្មវិធីបំណិនជីវិត ដែលអនុញ្ញាតអោយសិស្សធ្វើការ ស្រាវជ្រាវ ពីមុខជំនាញទូទៅ និង ជំនាញវប្បធម៌ពីសហគមន៍មកធ្វើការសិក្សា តែសាលាគ្មានគ្រូបង្រៀន ហេតុដូចនេះហើយ ទើបពួកខ្ញុំចុះ ស្រាវជ្រាវដើម្បីស្វែងរកអ្នក ចេះដឹងទៅបង្រៀនមួយរយ:ពេលខ្លីដល់ពួកខ្ញុំ ។ តើពួកខ្ញុំសុំការអនុញ្ញាត ពី ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស /ស្រី. លោកតា /លោកយាយ) សួរពត៌មានមួយចំនួនបានដែរឬទេ?

-ប្រជាជន: -បើឆ្លើយថា មិនបានទេដោយសាររវល់/ជាប់............ .......ត្រង់នេះយើង មិនបាច់សួរ អ្វីទៀត នោះទេ គ្រាន់តែនិយាយទៅកាន់គាត់ថា បើដូច្នេះ ពួកខ្ញុំសូមអរគុណច្រើន និងសូម គោរពលាសិនហើយ ។

- បើឆ្លើយថា បានមិនអីទេ( ប្អូន. ក្មួយ. ចៅ ។ល ។ ) យើងនឹងសួរបន្តទៀត ។

-សិស្ស: សុំទោស( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/លោកយាយ ។ល ។ ) ឈ្មោះអ្វី?

-ប្រជាជន: ខ្ញុំឈ្មោះ ............................ភេទ?..................អាយុ?................................

-សិស្ស: តើ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/លោកយាយ ។ល ។ ) ចេះជំនាញអ្វីខ្លះ?

-ប្រជាជន: ខ្ញុំចេះ:............................................................................................

-សិស្ស:តើ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. ។ល ។ ) ប្រកបមុខរបររនេះ បានប៉ុន្មានឆ្នាំហើយ?

-ប្រជាជន: ខ្ញុំចេះ:ប្រហែល.....................................................ហើយ

-សិស្ស: ប្រសិនជាសាលាអញ្ជើញ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/លោកយាយ) ទៅបង្រៀននៅសាលាពួកខ្ញុំ តើ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/លោកយាយ) ព្រមទៅទេ ? ករណីគាត់សួរពីការឧបត្ថម្ភ គួរប្រាប់ថា ( ការឧបត្ថម្ភ ២.០០០រៀលក្នុង១ម៉ោង)

-ប្រជាជន: ព្រម/ មិនព្រម

➧ សិស្ស: ពួកខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណដល់ ( បងប្រុស/ស្រី. ពូ/មីង. អ៊ំប្រុស/ស្រី. លោកតា/ លោកយាយ) ដែលបានលះបង់ពេលវេលាផ្តល់ការសម្ភាសន៍ដល់ពួកខ្ញុំ ។ សូមជម្រាបលា !

